00942147

002/19-09-2007-ECCC/TC
E1/185

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 07 / 2013
ម៉ោង (Time/Heure): 14:15 pm
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ចន្ទទី ២៩ ខែ មេសា ឆ្នាំ ២០១៣

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ១៧២

**រៀបចំដោយ៖ ឌុច ផារី និង Matteo CRIPPA**

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក RAYNOR Keith, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ ខៀវ សំផន និង នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, |

| |
|---|
| លោក ឡេា ជុនធី, លោក វ៉ែន ពៅ, លោក សំ សុគង់, លោកស្រី ជេត វណ្ណលី |
| អ្នកជំនាញ៖ (មិនមាន) |
| សាក្សី/ដើមបណ្ដឹងរដ្ឋប្បវេណី៖ ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន (TCCP-186), សាក្សី អ៊ុង ឆាត (TCW-752) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី ស្វ សុទ្ធាវី, លោក អ៊ុច អារុណ, លោក ឡាយ ណារ៉ា, លោកស្រី Seynabou DIOP |
| ផ្សេងៗ៖ កញ្ញា Elburg van BOETZELAER, មេធាវីប្រឹក្សាសាក្សី មឿន សុវណ្ណ |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.២៥ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៥០ | បញ្ចប់ម៉ោង៖ ១៣.៥០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៣ ម៉ោង និង ៥៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | អង្គជំនុំជម្រះ | ០៩.០៧ | ០៩.០៩ |
| ការស្ដាប់នូវសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន (TCCP-186) | អង្គជំនុំជម្រះ | ០៩.១០ | ០៩.១៦ |
| | សហមេធាវីនាំមុខ/វេណី | ០៩.១៥ | ១១.០៣ |
| | សហព្រះរាជអាជ្ញា | ១១.០៤ | ១១.១៩ |
| ការពិភាក្សាលើសំណើសុំវិធានការការពាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន (TCCP-186) និងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យធ្វើសវនាការជាអសាធារណៈ | មេធាវីការពារក្ដី ខៀវ សំផន | ១១.១៩ | ១១.២១ |
| | មេធាវីការពារក្ដី នួន ជា | ១១.២១ | ១១.២២ |
| | សហព្រះរាជអាជ្ញា | ១១.២២ | ១១.២៦ |
| | សហមេធាវីតំណាង/វេណី | ១១.២៨ | ១១.២៩ |
| | សហព្រះរាជអាជ្ញា | ១១.៣៦ | ១១.៣៨ |
| | មេធាវីការពារក្ដី ខៀវ សំផន | ១១.៣៨ | ១១.៤០ |

| | | | |
|---|---|---|---|
| | អង្គជំនុំជម្រះ | ១១.៤១ | ១១.៤៨ |
| | | ១៣.៥១ | ១៣.៥២ |
| | សហមេធាវីតំណាង/ដេណី | ១៣.៥២ | ១៣.៥៣ |
| | អង្គជំនុំជម្រះ | ១៣.៥៣ | ១៤.០២ |
| | សហមេធាវីតំណាង/ដេណី | ១៤.០៤ | ១៤.០៣ |
| | អង្គជំនុំជម្រះ | ១៤.០៣ | ១៤.០៥ |
| | សហព្រះរាជអាជ្ញា | ១៤.០៥ | ១៤.០៨ |
| | សហមេធាវីតំណាង/ដេណី | ១៤.០៨ | ១៤.១០ |
| | អង្គជំនុំជម្រះ | ១៤.១០ | ១៤.២៤ |
| | មេធាវីការពារក្តី នួន ជា | ១៤.២៤ | ១៤.២៦ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៤.២៦ | ១៤.២៩ |
| | សហមេធាវីតំណាង/ដេណី | ១៤.២៩ | ១៤.៣១ |
| | អង្គជំនុំជម្រះ | ១៤.៣៦ | ១៤.៣៨ |
| ការស្តាប់នូវសក្ខីកម្មរបស់សាក្សី អ៊ុង ឆាត់ (TCW-752) | អង្គជំនុំជម្រះ | ១៥.០៥ | ១៥.១៥ |
| | សហព្រះរាជអាជ្ញា | ១៥.១៥ | ១៦.០០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

អនុលោមតាមសេចក្តីសម្រេចលើកទីពីរស្តីពីបញ្ហាសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ ជនជាប់ចោទ នួន ជា ត្រូវបានអនុញ្ញាតឱ្យមានវត្តមាននៅត្រឹមបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១ (៥) ។

**ការស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ សារិន** (TCCP-186)

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ទាប់មកការ តាំងសំណួរបន្តដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ។

**ការពិភាក្សាលើសំណើសុំវិធានការការពាររបស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ សារិន** (TCCP-186) **និងសំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើសវនាការដាច់ដោយឡែកដើម្បីវាយតម្លៃលើសំណើរបស់ដើម**

**បណ្ដឹងរដ្ឋប្បវេណី ស សារិន** (TCCP-186)

បន្ទាប់ពីសម្រាកនៅពេលព្រឹក ដើមបណ្ដឹងរដ្ឋប្បវេណីបានបដិសេធមិនឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដោយគាត់មានការព្រួយបារម្ភពីបញ្ហាសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ។ ហេតុដូច្នេះហើយ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះស្នើសុំដល់អង្គជំនុំជម្រះថា៖ សុំឱ្យអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាផ្ដល់ឱ្យគាត់នូវវិធានការការពារអស់មួយជីវិត ។ គាត់ស្នើសុំឱ្យមានមន្ត្រីប៉ូលីស ០៤ នាក់តាមការពារគាត់រហូតដល់គាត់អស់ជីវិត ។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនព្រមផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះទេ ទោះបីជាសក្ខីកម្ម នោះធ្វើឡើងជាអសាធារណៈក៏ដោយ ។ សហព្រះរាជអាជ្ញាស្នើសុំធ្វើសវនាការជាអសាធារណៈដើម្បីដោះស្រាយលើសំណើនេះ។ មេធាវីការពារក្ដីទាំងពីរក្រុមជម្ទាស់ទៅនឹងការធ្វើសវនាការជាអសាធារណៈ ។ ដោយអង្គជំនុំជម្រះមិនមាននូវយុត្តាធិការក្នុងការផ្ដល់នូវវិធានការការពារដល់ដើមបណ្ដឹងរដ្ឋប្បវេណី ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើរសុំ និងបញ្ចប់ការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ។

**ការស្ដាប់នូវសក្ខីកម្មរបស់សាក្សី អ៊ុច ឆាត់** (TCW-752)

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនដល់សាក្សី។ បន្ទាប់មកការតាំងសំណួរបន្តដោយសហព្រះរាជអាជ្ញា។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| លេខ E3 | លេខ កសចស | ERN | ចំណងជើង | ចំណាត់ថ្នាក់ | សម្គាល់ជាភាសាខ្មែរ | សម្គាល់ជាភាសាអង់គ្លេស | សម្គាល់ជាភាសាបារាំង |
|---|---|---|---|---|---|---|---|
| E3/4596 | D230/1.1.874c | 00482761-00482840<br>00739493-00739570<br>00746443-00746511 | បទសម្ភាសន៍ជាមួយដើមបណ្ដឹង ស សារិន SAR Sarin<br>Interview of complainant SAR Sarin ស សារិន<br>Interview de plaignant SAR Sarin ស សារិន | P | 00482836, 00482822 | 00739552 | 00746507, 00746494 |
| E3/4597 | D230/1.1.874d | 00482841-00482841 | របាយការណ៍ស្ដីពីវិធានការកាពារខ្លួនរបស់ដើមបណ្ដឹង ស សារិន | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/4598 | D125/176 | 00277327-00277337<br>00284415-00284424<br>00352327-00352338 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី UNG Chhăt អ៊ុង ឆាត់<br>Written Record of Interview of UNG Chhăt អ៊ុង ឆាត់<br>Procès verbal d'audition de KHEU Hun | P | | | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញនាំដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (TCCP-186) ត្រឡប់ទៅកាន់គេហដ្ឋានរបស់គាត់វិញ។
- អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (TCCP-186) ដែលបានស្នើសុំវិធានការការពារពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដោយអង្គជំនុំជម្រះមិនមាននូវសិទ្ធិសម្រេចលើបញ្ហានោះ ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សី អ៊ុង ឆាត់ (TCW-752) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់វិញ និងបង្គាប់ឱ្យនាំគាត់មកកាន់សាលសវនាការវិញនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ឱ្យបានមុនម៉ោង ៩.០០ នាទី ព្រឹក ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឱ្យនាំជនជាប់ចោទ ខៀវ សំផន មកកាន់សាលសវនាការវិញ និងជនជាប់ចោទ នួន ជា មកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ឱ្យបានមុនម៉ោង ០៩.០០ នាទី ព្រឹក ។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ វេលាម៉ោង ៩ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣
ក្រឡាបញ្ជី

ឌុច ផារី Matteo CRIPPA